ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រមសីលធម៌សម្រាប់
# សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត

រៀបចំដោយសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត

ខែកក្កដា ឆ្នាំ ២០២១



# អារម្ភកថា

ក្រុមប្រឹក្សារាជធានី ខេត្ត មានតួនាទីពិនិត្យ និងធ្វើសេចក្តីសម្រេចផ្សេងៗ ទាក់ទងនឹងកិច្ចការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម ដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែង និងបន្ទាន់របស់ប្រជាពលរដ្ឋ ស្របតាមអាណត្តិទូទៅ មុខងារ និងធនធានដូចមានចែងក្នុងច្បាប់ ក្របខ័ណ្ឌគោលនយោបាយជាតិ និងវិធានចាំបាច់ជាធរមានទាំងឡាយ ក៏ដូចជាបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារាជធានីខេត្តសាមី។

ដើម្បីបំពេញការងារឱ្យមានប្រសិទ្ធភាព ក្រមសីលធម៌ត្រូវបានរៀបចំ និងដាក់ឱ្យប្រើប្រាស់នៅឆ្នាំ២០១៤។ នៅពេលដែលមុខងារ និងធនធានរដ្ឋបាលត្រូវបានផ្ទេរ

កាន់តែច្រើនឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រមសីលធម៌នេះ ក៏ត្រូវបានធ្វើបច្ចុប្បន្នភាពផងដែរ ដើម្បីសម្រួលការបំពេញការងាររបស់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ឱ្យស្របទៅតាមមុខងារ និងធនធានដែលបានផ្ទេរជាបន្តបន្ទាប់ សំដៅលើកកម្ពស់ និងបង្កើនគុណភាពក្នុងការផ្ដល់សេវាជូនប្រជាពលរដ្ឋប្រកបដោយនវានុវត្តន៍ បរិយាប័ន្ន និងសមធម៌។

បច្ចុប្បន្នភាពនៃក្រមសីលធម៌នេះ គឺដើម្បីបង្កលក្ខណៈងាយស្រួលដល់សមាជិកក្រុមប្រឹក្សាក្នុងការស្វែងយល់ គោរព និងអនុវត្តដោយប្រកាន់ខ្ជាប់នូវគុណតម្លៃសំខាន់ៗ ដូចជា ការគោរពគ្នាទៅវិញទៅមក សេចក្ដីថ្លៃថ្នូរ សុចរិតភាព និងភាពមិនលំអៀង។

សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត មានក្ដីសោមនស្សរីករាយចំពោះ ការទទួលធាតុចូលពីសំណាក់សមាជិកក្រុមប្រឹក្សារាជធានី ខេត្តក្នុងដំណើរការធ្វើបច្ចុប្បន្នភាពក្រមសីលធម៌នេះ ព្រមទាំងត្រៀមខ្លួនជានិច្ចក្នុងការពិគ្រោះយោបល់ ដើម្បីអនុវត្តក្រមសីលធម៌ឲ្យទទួលបាន

លទ្ធផលល្អ។

ខ្ញុំមានក្តីសង្ឃឹមថា ក្រមសីលធម៌នេះ គឺជាត្រីវិស័យសម្រាប់បណ្តុះគំនិតស្មារតី និងតម្រង់ទិសទៅរកឥរិយាបថល្អៗ របស់សមាជិកក្រុមប្រឹក្សាម្នាក់ៗ ដើម្បីរួមចំណែកក្នុងការផ្តល់សេវាដែលឆ្លើយតបនឹងបំណងប្រាថ្នា និងតម្រូវការជាក់ស្តែង និងបន្ទាន់របស់ប្រជាពលរដ្ឋ អនុលោមតាមអាណត្តិទូទៅ ការផ្ទេរមុខងារ និងធនធាន និងគោលការណ៍អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ថ្ងៃសុក្រ ៧កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០២១

ប្រធាន

ប៉ា សុជាតិវង្ស

# គោលបំណង

**ប្រការ ១៖** ក្រមសីលធម៌សម្រាប់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើត និងធ្វើបច្ចុប្បន្នភាពផ្អែកតាមតម្រូវការចាំបាច់សម្រាប់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ដោយមានគោលបំណងដូចខាងក្រោម៖

- លើកកម្ពស់ការអនុវត្តតួនាទី និងភារកិច្ចប្រកបដោយសុចរិតភាព។
- លើកកម្ពស់គុណតម្លៃ និងសេចក្ដីថ្លៃថ្នូររបស់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត។
- លើកកម្ពស់គុណភាព និងប្រសិទ្ធភាពក្នុងការផ្ដល់សេវាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ច។
- លើកកម្ពស់ការការពារសិទ្ធិចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចការរបស់រដ្ឋបាលគ្រប់លំដាប់ថ្នាក់។

**ប្រការ ២៖** ក្រមសីលធម៌កំណត់អាកប្បកិរិយា ឥរិយាបថ និងករណីយកិច្ចទាំងឡាយ សម្រាប់សមាជិកក្រុមប្រឹក្សា ត្រូវប្រកាន់ខ្ជាប់ក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ប្រកបដោយមនសិការវិជ្ជាជីវៈ។

**ប្រការ ៣៖** ក្រមសីលធម៌នេះ មានវិសាលភាពគ្រប ដណ្តប់លើសមាជិក ក្រុមប្រឹក្សារាជធានី ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៤៖** សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវប្រកាសថា បានអាន បានយល់ច្បាស់អំពីខ្លឹមសារ និងស្មារតីនៃបច្ចុប្បន្នភាពក្រមសីលធម៌នេះ និងចូលរួមគោរពប្រតិបត្តិទាំងអស់គ្នា។

# មូលដ្ឋានច្បាប់
# និងគោលការណ៍អភិបាលកិច្ច

**ប្រការ ៥៖** ក្រមសីលធម៌នេះ គឺជាឯកសារជំនួយស្មារតីសម្រាប់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវប្រកាន់ខ្ជាប់ក្នុងការអនុវត្តការងារក្នុងនាម និងក្នុងភាពជាតំណាងឱ្យប្រជាពលរដ្ឋទាំងអស់ស្ថិតក្នុងរាជធានី ខេត្ត។

**ប្រការ ៦៖** ក្រមសីលធម៌នេះ ត្រូវបានរៀបចំឡើងដោយយោងតាមបទប្បញ្ញត្តិ និងវិធានចាំបាច់ដែលតម្រូវឱ្យក្រុមប្រឹក្សាអនុវត្តដោយខានមិនបាន ដូចមានចែងក្នុងច្បាប់ និងបទបញ្ជាផ្ទៃក្នុង ដូចខាងក្រោម៖

1. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨។

2. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ ២០០១។

3. បទបញ្ញាផ្ទៃក្នុង ដែលត្រូវបានអនុម័ត និងប្រកាសដាក់ឲ្យប្រើប្រាស់ដោយសាមីក្រុមប្រឹក្សារាជធានី ខេត្ត នីមួយៗ។

4. លក្ខន្តិកៈរបស់សមាគមជាតិក្រុមប្រឹក្សារាជធានីខេត្ត។

**ប្រការ ៧៖** សមាជិកក្រុមប្រឹក្សាគ្រប់រូប ត្រូវរួមចំណែកក្នុងការថែរក្សា និងលើកកម្ពស់តម្លៃ និងសេចក្តីថ្លៃថ្នូររបស់ក្រុមប្រឹក្សា ស្របតាមគោលការណ៍គ្រឹះនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដូចខាងក្រោម៖

- ភាពជាតំណាងសាធារណៈ
- ស្វ័យភាពរបស់មូលដ្ឋាន
- ការពិគ្រោះយោបល់ និងការចូលរួម
- ការឆ្លើយតប និងគណនេយ្យភាព
- ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជន នៅក្នុងមូលដ្ឋាន
- ការលើកស្ទួយសមធម៌
- តម្លាភាព និងសុចរិតភាព
- វិធានការប្រយុទ្ធប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច។

# គុណតម្លៃក្នុងភាពជាអ្នកដឹកនាំ

**ប្រការ៨៖** សមាជិកក្រុមប្រឹក្សាម្នាក់ៗមានកាតព្វកិច្ចរួមចំណែកលើកកម្ពស់គុណតម្លៃរបស់ក្រុមប្រឹក្សារាជធានីខេត្ត ឱ្យក្លាយជានីតិបុគ្គលនៃនីតិសាធារណៈខ្ពស់បំផុតនៅថ្នាក់ក្រោមជាតិដែលសាធារណជនទូទៅគាំទ្រ ជឿទុកចិត្ត និងចូលរួមលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យប្រកបដោយនិរន្តរភាព ស្របតាមគុណតម្លៃរួម ដូចខាងក្រោម៖

**សុចរិតភាព៖** ការបណ្តុះជំនឿទុកចិត្ត និងសេចក្តីស្រឡាញ់ពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះក្រុមប្រឹក្សា គឺអាស្រ័យលើមនសិការវិជ្ជាជីវៈខ្ពស់ ភាពគួរជឿទុកចិត្ត និងការគោរពពាក្យសន្យារបស់សមាជិកក្រុមប្រឹក្សាម្នាក់ៗ ក្នុងការរួមចំណែកដោះស្រាយ និងការពារផលប្រយោជន៍សាធារណៈ។

**សេចក្តីថ្លៃថ្នូរ៖** សេចក្តីថ្លៃថ្នូរ និងសីលធម៌របស់បុគ្គលម្នាក់ៗ រំលេចចេញតាមរយៈឯកសណ្ឋានជាក្រុមប្រឹក្សាក្នុងពេលបំពេញការងារ ការមិនបៀតបៀនកេរ្តិ៍ខ្មាស់ ការមិនសម្លុតគំរាមអ្នកដទៃតាមផ្លូវកាយ និងផ្លូវចិត្ត និងការចៀសវាងការប្រព្រឹត្តិខុសឆ្គងខាងសីលធម៌ធ្ងន់ធ្ងរផ្សេងៗ។

**ការគោរព៖** ការគោរពសិទ្ធិបញ្ចេញមតិរបស់សធារណជនគឺជាករណីយកិច្ចក្នុងភាពជាអ្នកដឹកនាំមូលដ្ឋាន ដោយមិនប្រកាន់និន្នាការ ឋានៈ ហើយត្រូវប្រព្រឹត្តចំពោះបុគ្គលសាធារណៈទូទៅ ប្រកបដោយសេចក្តីថ្លៃថ្នូរ សន្តានចិត្តល្អ និងអាណិតអាសូរដែលទង្វើប្រកបដោយគុណធម៌នេះ នឹងទទួលបានការគោរពស្រឡាញ់ពីសំណាក់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធវិញផងដែរ។

**ភាពជាអ្នកដឹកនាំល្អ៖** មានគុណធម៌ មានសមត្ថភាព និង

មានទស្សនៈវិស័យវែងឆ្ងាយក្នុងការធ្វើសេចក្តីសម្រេចចិត្ត ប្រកបដោយបរិយាប័ន្ន ដើម្បីផលប្រយោជន៍សាធារណៈ។ ភាពជាអ្នកដឹកនាំល្អ មានឥទ្ធិពលជាវិជ្ជមានក្នុងការ អភិវឌ្ឍធនធានមនុស្សក្នុងក្របខ័ណ្ឌរដ្ឋបាល និងសមត្ថកិច្ចមូលដ្ឋាន។

**សាមគ្គីភាព និងការរៀនសូត្រ៖** បង្កើតបរិយាកាស អំណោយផលល្អក្នុងកន្លែងធ្វើការ លើកកម្ពស់របៀបរបប ធ្វើការងារមានលក្ខណៈចម្រុះ និងផ្តល់ឱកាសស្មើភាព ដើម្បីចែករំលែកចំណេះដឹង បទពិសោធន៍ និងរៀនសូត្រពីគ្នាទៅវិញទៅមកក្នុងជួរក្រុមប្រឹក្សា ឬរៀនសូត្រពីដៃគូស្ថាប័នពាក់ព័ន្ធ និងក្រុមប្រឹក្សានៅតាមប្រភេទផ្សេងៗ។

**ភាពត្រឹមត្រូវ និងយុត្តិធម៌៖** ការប្រព្រឹត្តដោយស្មើភាព និងដោយគ្មានការរើសអើងចំពោះប្រជាពលរដ្ឋ ពិសេស ស្ត្រី ក្មេងស្រី ក្រុមជនងាយរងគ្រោះ និងជនជាតិដើមភាគតិច។

# ក្រមសីលធម៌
# អតិបរមាសម្រាប់ការផ្តល់សេវាកម្ម

**ប្រការ ៩៖** សមាជិកក្រុមប្រឹក្សាត្រូវរៀបចំឥរិយាបទ និងប្រតិបត្តិប្រការនៃក្រមសីលធម៌ ដើម្បីតម្រង់ទិស ក្រុមប្រឹក្សាក្នុងការចាត់ចែង ការគ្រប់គ្រង ការប្រើប្រាស់ តួនាទី និងសិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យស្របតាមច្បាប់ជាធរមាន ដើម្បីបង្កើនជំនឿទុកចិត្ត របស់ប្រជាពលរដ្ឋ និងសហគមន៍។

## ការប្រកាន់ឥរិយាបថ និងអាកប្បកិរិយាសមរម្យ៖

ក្នុងភាពជាតំណាងរបស់ប្រជាពលរដ្ឋ សមាជិកក្រុម ប្រឹក្សាម្នាក់ៗ ត្រូវមានការប្រុងប្រយ័ត្នខ្ពស់ក្នុងការប្រើ ប្រាស់ឋានៈ តួនាទី និងសិទ្ធិអំណាចរបស់ខ្លួនឱ្យបាន ត្រឹមត្រូវក្នុងពេលបំពេញការងារជាផ្លូវការ ឬក្រៅម៉ោង ធ្វើការ និងត្រូវចៀសវាងការប្រើប្រាស់ តួនាទីនេះ ដើម្បី

បុព្វហេតុផ្ទាល់ខ្លួន ដែលអាចធ្វើឱ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ក្រុមប្រឹក្សាទាំងមូល។

សមាជិកក្រុមប្រឹក្សាម្នាក់ៗត្រូវប្រព្រឹត្តចំពោះគណៈអភិបាល និងមន្ត្រីក្រោមឱវាទ ប្រកបដោយការគោរព ការគួរសម និងសេចក្តីថ្លៃថ្នូរ។ ការគោរពគ្នាទៅវិញទៅមករវាងក្រុមប្រឹក្សា និងគណៈអភិបាលផ្តល់កេរ្តិ៍ឈ្មោះល្អសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយត្រូវថែរក្សាវប្បធម៌ល្អនេះឱ្យបានជានិច្ច។

**ការបំពេញការងារ និងការធ្វើសេចក្តីសម្រេច៖** ក្នុងនាមជានីតិបុគ្គលនៃនីតិសាធារណៈ សមាជិកក្រុមប្រឹក្សាម្នាក់ៗ ត្រូវមានស្មារតីទទួលខុសត្រូវខ្ពស់បំផុតក្នុងការលើកកម្ពស់ការការពារសិទ្ធិបញ្ចេញមតិរបស់ប្រជាពលរដ្ឋ ការបំពេញការងារ ការធ្វើសេចក្តីសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចចិត្តតាមការសន្យាជាមួយរដ្ឋបាល

ថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋ ហើយត្រូវដាក់ខ្លួនឲ្យស្ថិតនៅក្រោមវិន័យ និងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងច្បាប់ជាធរមាន និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា។

សមាជិកក្រុមប្រឹក្សាម្នាក់ៗ ត្រូវជម្រុញឱ្យមានការផ្សព្វផ្សាយព័ត៌មានស្តីពីធនធាន សេចក្តីសម្រេចចិត្ត និងវិធានការចាំបាច់ទាំងឡាយរបស់ក្រុមប្រឹក្សា លើកលែងតែព័ត៌មានសម្ងាត់ ដើម្បីឲ្យសាធារណជនទទួលបានព័ត៌មានតាមរយៈយន្តការដែលមានស្រាប់របស់ក្រុមប្រឹក្សា និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗក៏ដូចជាប្រព័ន្ធផ្សព្វផ្សាយសង្គម។

**ការកសាងទំនុកចិត្ត៖** ក្រុមប្រឹក្សារាជធានី ខេត្ត គឺជានិមិត្តរូប និងធ្វើសកម្មភាពក្នុងនាមប្រជាពលរដ្ឋដែលរស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ សមាជិកក្រុមប្រឹក្សា

ម្នាក់ៗ ត្រូវចូលរួមលើកកម្ពស់ជំនឿទុកចិត្តគ្នានៅក្នុងជួរក្រុមប្រឹក្សា បង្កើត និងធានាបរិយាកាសការងារប្រកបដោយភាពស្មោះត្រង់ និងធានាថា ធនធានរដ្ឋបាលត្រូវបានគ្រប់គ្រង និងប្រើប្រាស់ ដើម្បីជាប្រយោជន៍ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ។

**ការលើកកម្ពស់សមភាព៖** ក្រុមប្រឹក្សារាជធានី ខេត្ត ដែលជាយន្តការដឹកនាំខ្ពស់បំផុតរបស់រដ្ឋបាលរាជធានី ខេត្ត ត្រូវមានគណនេយ្យភាពខ្ពស់ និងមានការចូលរួមកាន់តែសកម្មក្នុងការការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋខ្មែរទាំងពីរភេទក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ជាតិ និងធានាសិទ្ធិទទួលបានសេវាពីក្រុមប្រឹក្សាដោយស្មើភាព គ្មានការរើសអើង គ្មានការយាយីពីបុគ្គល ឬក្រុមណាមួយ ដោយមិនប្រកាន់ពូជសាសន៍ សាសនា ពណ៌សម្បុរ ភេទ អាយុ ពិការភាព ឬនិន្នាការនយោបាយឡើយ។

**ការជានាមានពេលវេលាគ្រប់គ្រាន់៖** ក្រុមប្រឹក្សា គឺជាយន្តការ និងជាវេទិកាពិគ្រោះយោបល់របស់សាធារណជន សហគមន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងស្ថាប័នជំនាញពាក់ព័ន្ធនានា។ សមាជិកក្រុមប្រឹក្សាម្នាក់ៗ ត្រូវរៀបចំពេលវេលា ដើម្បីចូលរួមក្នុងវេទិកាសាធារណៈ និងកិច្ចសន្ទនាផ្សេងៗជាមួយប្រជាពលរដ្ឋ ដើម្បីស្វែងយល់អំពីវឌ្ឍនភាព បញ្ហាប្រឈម និងចូលរួមដោះស្រាយ និងធ្វើសេចក្ដីសម្រេចចិត្ត តាមរយៈ វេទិកាសាធារណៈ កិច្ចប្រជុំអាណត្តិ និងកិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាតាមការចាំបាច់។

**ការមានទំនាក់ទំនងការងារល្អ៖** សមាជិកក្រុមប្រឹក្សាម្នាក់ៗ ត្រូវផ្ដល់តម្លៃខ្ពស់ក្នុងការបង្កើត និងថែរក្សាទំនាក់ទំនងល្អ និងសុខដុមនីយកម្មក្នុងក្របខ័ណ្ឌរដ្ឋបាលរបស់ខ្លួន និងជាមួយស្ថាប័នជំនាញពាក់ព័ន្ធ វិស័យឯកជន សហគមន៍ និងប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល ដើម្បី

សម្របសម្រួលសកម្មភាពផ្តល់សេវារបស់តួអង្គពាក់ព័ន្ធ ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ប្រកបដោយប្រសិទ្ធភាព គុណភាពខ្ពស់ និងទាន់ពេលវេលា។ ការប្រាស្រ័យទាក់ទង និងទំនាក់ទំនងការងារល្អ គឺជាបុរេលក្ខខណ្ឌរបស់សមាជិកក្រុមប្រឹក្សាក្នុងការស្វែងរកការគាំទ្រលើកិច្ចការផ្សេងៗ ទទួលបានជោគជ័យ។

**ការកៀរគរ និងស្វែងរកការគាំទ្រ៖** សមាជិកក្រុមប្រឹក្សាម្នាក់ៗ ត្រូវរួមចំណែកពង្រឹងកិច្ចសហប្រតិបត្តិការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិនៅគ្រប់កម្រិត និងតួអង្គពាក់ព័ន្ធទាំងអស់ ដើម្បីកៀរគរធនធានសម្រាប់អនុវត្តយុទ្ធសាស្រ្តអភិវឌ្ឍន៍រាជធានី ខេត្តឱ្យសម្រេចបានលទ្ធផលល្អ។ សមាជិកក្រុមប្រឹក្សាម្នាក់ៗ ត្រូវរៀនសូត្រ និងចែករំលែកមេរៀន និងបទពិសោធន៍ល្អៗ ពីគម្រោងសហប្រតិបត្តិការជាមួយដៃគូផ្សេងៗ និងបន្តបញ្ចុះបញ្ចូល និងស្វែង

រកការគាំទ្របន្ថែមពីស្ថាប័ន និងដៃគូអភិវឌ្ឍន៍នៅថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីគាំទ្រក្នុងការអនុវត្តវិធានការបន្ទាន់( ឧទាហរណ៍ ករណីជំងឺឆ្លងរាតត្បាត គ្រោះធម្មជាតិធ្ងន់ធ្ងរ ) និងសេចក្តីសម្រេចចិត្តជាយុទ្ធសាស្រ្តរបស់ក្រុមប្រឹក្សាប្រកបដោយនវានុវត្តន៍ បរិយាប័ន្ន និងសមធម៌សង្គម។

## ការប្រព្រឹត្តខុសឆ្គង

**ប្រការ ១០៖** សមាជិកក្រុមប្រឹក្សារាជធានី ខេត្តគ្រប់រូប ត្រូវចៀសវាងជាដាច់ខាតនូវការប្រព្រឹត្តិអំពើខុសឆ្គងដូចខាងក្រោម៖

**អំពើល្មើស៖** សមាជិកក្រុមប្រឹក្សា ត្រូវចៀសវាងដាច់ខាតនូវសកម្មភាពល្មើសច្បាប់ជាធរមាន និងបទបញ្ជាផ្ទៃក្នុង និងគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

**ការគំរាមកំហែង និងការបៀតបៀនកេរ្តិ៍ខ្មាស់៖**
សមាជិកក្រុមប្រឹក្សា ត្រូវចៀសវាងជាដាច់ខាតនូវអំពើបៀតបៀនកេរ្តិ៍ខ្មាស់ ការបំភិតបំភ័យ ការឃាយី រំខាន ឬការរំលោភបំពានដោយផ្លូវកាយ និងផ្លូវចិត្ត ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន។

**ការរើសអើង៖** សមាជិកក្រុមប្រឹក្សា ត្រូវចៀសវាងការរើសអើងដោយសារភេទ ពូជសាសន៍ ពណ៌សម្បុរ ជនជាតិ ជាពិសេសសហគមន៍ និងក្រុមជនងាយរងគ្រោះ ស្ត្រី និងកុមារ និងមិនត្រូវលម្អៀងក្នុងការផ្តល់សេវាឡើយ ទោះបីជាអ្នកទទួលសេវា មានកត្តាសង្គម វប្បធម៌ និងទស្សនៈនយោបាយយ៉ាងណាក្តី។

**ទំនាស់ផលប្រយោជន៍៖** សមាជិកក្រុមប្រឹក្សាម្នាក់ៗ ត្រូវចូលរួមទប់ស្កាត់រាល់ការប៉ុនប៉ងណាមួយក្នុងការប្រើប្រាស់តួនាទី មុខតំណែងផ្លូវការរបស់បុគ្គលណាម្នាក់ ដើម្បីទាញយកផលចំណេញក្នុងរូបភាពជាប្រយោជន៍

ផ្ទាល់ខ្លួន ប្រយោជន៍វិជ្ជាជីវៈ និងអាជីវកម្មរបស់ខ្លួន ឬភ្ជាប់តួនាទីផ្លូវការរបស់ខ្លួនជាមួយអ្នកដទៃទៀតក្នុង ទំនាក់ទំនងជាលក្ខណៈផ្ទាល់ខ្លួន ឬជាលក្ខណៈគ្រួសារ ឬជាលក្ខណៈបក្សពួកនិយម។

សមាជិកក្រុមប្រឹក្សាណាម្នាក់ដែលដឹងថាខ្លួនអាច ឬមានការជាប់ពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍ ត្រូវ ប្រកាសអំពីជំហររបស់ខ្លួនក្នុងកិច្ចប្រជុំធ្វើសេចក្តីសម្រេច ចិត្ត ដើម្បីសុំការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាមិនចូល រួមពិភាក្សា ឬមិនចូលរួមក្នុងការធ្វើការសម្រេចចិត្ត។

**ការធ្វើសេចក្តីអត្ថាធិប្បាយជាសាធារណៈ៖** សមាជិក ក្រុមប្រឹក្សា ត្រូវចៀសវាងការធ្វើសេចក្តីអត្ថាធិប្បាយលើ កិច្ចការអ្វីមួយរបស់ក្រុមប្រឹក្សាជាមួយប្រព័ន្ធផ្សព្វផ្សាយ ផ្សេងៗ ដោយមិនមានការប្រគល់ភារកិច្ចច្បាស់លាស់ ពីប្រធានក្រុមប្រឹក្សា។

# ការដោះស្រាយបញ្ហា
# ពាក់ព័ន្ធនឹងការប្រព្រឹត្តខុសឆ្គង

**ប្រការ ១១៖** ក្រមសីលធម៌នេះ គឺជាឯកសារជំនួយស្មារតីសម្រាប់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ជាប់ឆ្នោតត្រូវប្រកាន់ខ្ជាប់ ស្របតាមច្បាប់ជាធរមាន និងគោលការណ៍អភិបាលកិច្ចល្អរបស់ព្រះរាជាណាចក្រកម្ពុជា។

ក្នុងករណីមានការរំលោភ និងបំពានដោយចេតនា និងធ្ងន់ធ្ងរលើក្រមសីលធម៌នេះ បុគ្គលជាសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវទទួលខុសត្រូវយោងទៅតាមបទប្បញ្ញត្តិចាំបាច់នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា។

ក្នុងករណីមានការបំពានធ្ងន់ធ្ងរ ប្រធានក្រុមប្រឹក្សារាជធានី ខេត្តត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរជូនក្រសួងមហាផ្ទៃ និងសមាគមជាតិក្រុមប្រឹក្សារាជធានីខេត្ត អំពីវិធានការដែលក្រុមប្រឹក្សារាជធានី ខេត្ត បានអនុវត្តចំពោះករណីរំលោភបំពាននោះ ឬស្នើសុំវិធានការដោះស្រាយតាមផ្លូវច្បាប់។

## អគ្គលេខាធិការដ្ឋាន

ស្ថិតក្នុងបរិវេណព្រឹទ្ធសភា (វិមានរដ្ឋចំការមន)
មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ៖ ០២៣ ២៣៨ ០៨០
អ៊ីម៉ែល៖ darapok@online.com.kh
គេហទំព័រ៖ www.clga.com.kh



## សហការ និងគាំទ្រដោយ

បោះពុម្ពលើកទី២ ចំនួន ១០០០ ច្បាប់